**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
★★★★★★

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន**
លេខ..........................កសក

ថ្ងៃ......................ខែ..................ឆ្នាំ..............ស័ក ព.ស ២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ...........ឆ្នាំ២០២........

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**កម្មវត្ថុ ៖** របាយការណ៍វឌ្ឍនៈភាពការងារអនុវត្តគម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន ប្រចាំខែកក្កដា ឆ្នាំ ២០២៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបអំពីវឌ្ឍនៈភាពការងារអនុវត្តគម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន ប្រចាំខែកក្កដា ឆ្នាំ២០២៣ ដូចតទៅ។

## I. សេចក្តីផ្តើម

គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន គឺជាគម្រោងដែលមានសកម្មភាព៖ ១) ជួយគាំទ្រដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រាជរដ្ឋាភិបាល ដែលមានបំណងធ្វើអោយប្រសើរឡើងនូវការប្រកួតប្រជែងនៃខ្សែច្រវាក់ផលិតកម្មនៅក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ កំពត និងតាកែវ ។២) ជំរុញភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ នៃហេដ្ឋារចនាសម្ព័ន្ធកសិកម្មសំខាន់ៗ និងជួយក្នុងការធ្វើពាណិជ្ជកម្មលើផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី និងស្វាយ។ ៣) ជួយបង្កើនផលិតភាព និងពិពិធកម្មដំណាំ ការកែរលំអសមត្ថភាពឃ្លាំងស្តុក ការកែច្នៃ និងការធ្វើតេស្តគុណភាព និងសុវត្ថិភាពផលិតផល ព្រមទាំងលើកកំពស់ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ និងជីវថាមពល។ ៤) ពង្រឹងសមត្ថភាព ទាំងបច្ចេកទេស និងស្ថាប័ន សម្រាប់កសិកម្មវៃឆ្លាតដែលធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ (Climate Smart Agriculture) និងបង្កើតបិរយាកាសគោលនយោបាយមួយដែលអាចធ្វើទៅបាន សំរាប់អាជីវកម្មប្រកបដោយភាតរៈបរិស្ថាន។ លើកកំពស់និរន្តរភាពបរិស្ថាន ហើយនិងបង្កើនប្រាក់ចំណូល សំរាប់កសិករ និងអាជីវករក្នុងរយៈពេលវែង ។

គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន ចែកចេញជា៣សមាសភាគ ៖

**សមាសភាគទី១៖ កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវាក់ផលិតកម្មកសិកម្ម អោយមានភាពប្រសើរឡើងហើយដែលធន់នឹងបម្រែបម្រួលអាកាសធាតុ**

១) ការស្តារប្រព័ន្ធធារាសាស្រ្ត និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក (ប្រព័ន្ធធារាសាស្ត្រ ស្រះទឹក និងប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក) ដែលមានលក្ខណៈធន់ទ្រាំទៅនឹងបម្រែបម្រួលអាកាសធាតុ។

២) ធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវាក់តម្លៃរបស់សហគមន៍កសិកម្ម (លានហាលកសិផល ដំណើរការផលិត និងឃ្លាំងស្តុក។l

៣) ធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ពីស្រែទៅសហគមន៍ និងទៅទីផ្សារតាមរយៈបណ្តាញផ្លូវលំជនបទដែលធន់ទ្រាំនឹងបម្រែបម្រួលអាកាសធាតុ

៤) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់គុណភាពកសិកម្មនិងការធ្វើតេស្តសុវត្ថិភាព នៅមន្ទីពិសោធន៍កសិកម្មជាតិ និង

៥) ការលើកកម្ពស់ថាមពលដែលអាចប្រើឡើងវិញបាន (ឡជីវឧស្ម័ន និងការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យក្នុងតំបន់សហគមន៍កសិកម្មគោលដៅ) ដើម្បីកែលម្អខ្សែច្រវាក់តម្លៃ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ Green House Gas (GHG) ។

**សមាសភាគទី២៖ ជំរុញការអនុវត្តន៍កសិកម្មវៃឆ្លាត និងកសិធុរៈកិច្ចអោយមានលក្ខណៈស្របទៅនឹងអាកាសធាតុ**

១) បញ្ចេញពូជដែលធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ

២) ការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តផលិតកម្មភាតរៈបរិស្ថាននិងបច្ចេកវិទ្យា

៣) លើកកម្ពស់គ្រឿងយន្តកសិកម្មនិងការផ្សព្វផ្សាយ

គម្រោងនឹងបណ្តុះបណ្តាលកសិករយ៉ាងហោចណាស់ ៤០ ០០០នាក់ (១៦ ០០០នាក់ជាស្រ្តី) ស្តីពីកសិកម្មវៃឆ្លាតដែលធន់នឹងបម្រែបម្រួលអាកាសធាតុ។ មិនតែប៉ុណ្ណោះគម្រោងនឹងធ្វើបង្ហាញអំពី ការកៀរពង្រាបដីដោយប្រព័ន្ធកាំរស្មីឡាស៊ែដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពការប្រើប្រាស់ទឹក និងលើកកម្ពស់សមត្ថភាពក្រុមកសិករប្រើប្រាស់ទឹកក្នុងការប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធធារាសាស្រ្ត។ គម្រោងនឹងសាងសង់ និងធ្វើឲ្យប្រសើរឡើងនូវរោងជាងជួសជុលគ្រឿងយន្តកសិកម្ម (Mechanization Engineering Workshop) ៤ កន្លែង នឹងបំពាក់សម្ភារៈ មជ្ឈមណ្ឌលបណ្តុះបណ្តាល កសិ-ធុរៈកិច្ច(Provincial Agriculture Development Center) ៤កន្លែង ដើម្បីបណ្តុះបណ្តាលសហគមន៍កសិករប្រើប្រាស់ទឹក កសិករជាស្រ្តី និងសមាជិកសហគមន៍កសិកម្មក្នុងការគ្រប់គ្រង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងយន្តកសិកម្ម។

**សមាសភាគទី៣៖ ការរៀបចំឲ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគកសិ-ធុរៈកិច្ចប្រកបដោយភាតរៈបរិស្ថាន**

១) បង្កើតស្តង់ដារនិងគោលនយោបាយកសិ-ធុរៈកិច្ចប្រកបដោយភាតរៈបរិស្ថាន

២) ជម្រុញហិរញ្ញប្បទានបៃតង និងយន្តការចែករំលែកហានិភ័យ និង

៣) គាំទ្រការគ្រប់គ្រងហានិភ័យអាកាសធាតុ តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។

គម្រោងនឹងផ្តល់ជូននូវវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មកសិកម្ម គុណភាព និងស្តង់ដារភាពសុំា ក្នុងនោះរួមមានការអនុវត្តកសិកម្មល្អកម្ពុជា និងស្តង់ដារជីសរីរាង្គ។ គម្រោងនិងគាំទ្រសហគមន៍កសិកម្មក្នុងការប្រកបអាជីវកម្មកសិ-ធុរៈកិច្ចប្រកបដោយនិរន្តភាពដោយផ្សារភ្ជាប់ជាមួយវិស័យឯកជន និងដោយបង្កើនវេទិកាភាពជាដៃគូរវាងរដ្ឋនិងឯកជន

ដោយផ្តោតទៅលើដំណាំ។ គម្រោងនឹងបង្ហាញនូវចំណេះដឹងនៃស្ថាប័នហិរញ្ញវត្ថុ ស្តីពីហិរញ្ញប្បទានបៃតង និងការធ្វើសមាហរណកម្ម វិនិច្ឆ័យជម្រុះហានិភ័យអាកាសធាតុ និងបរិស្ថានទៅក្នុងការអនុវត្តប្រព័ន្ធក្រេឌីត និងនីតិវិធីធ្វើរបាយការណ៍។ គម្រោងនឹងផ្តល់ព័ត៌មានអាកាសធាតុ ទីផ្សារ និងក្សេត្រសាស្ត្រដើម្បីបង្កើតបរិយាកាសមួយសម្រាប់ការគ្រប់គ្រងហានិភ័យអាកាសធាតុកាន់តែមានប្រសិទ្ធភាព ដោយការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន បានទទួលកម្ចីឥណទាន និងជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានរយៈពេល ៧ឆ្នាំ ៦ខែ ដែលចាប់អនុវត្តពីខែតុលា ឆ្នាំ២០១៨ និងបញ្ចប់នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២៦។ គម្រោងមានថវិកាសរុប ១៤១, ០៤០, ០០០ លានដុល្លាអាមេរិក ក្នុងនោះ (៩០លានដុល្លារអាមេរិក ថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង១០ លានដុល្លាអាមេរិច ថវិកាកម្ចីពីមូលនិធិអាកាធាតុបៃបង (Green Climate Fund) ចំណែកឯ៣០លានដុល្លាអាមេរិក ថវិកាជំនួយឥតសំណងពីមូលនិធិអាកាធាតុបៃបង។ ៧, ៣៨ លានដុល្លាអាមេរិច ថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា និង៣, ៦៦ លានដុល្លាអាមេរិច ជាថវិកាបដិភាគពីអ្នកទទួលផល) ដែលដឹកនាំអនុវត្តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (Executive Agency) និងដែលមានក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹកនិងឧតុនិយម ជាភ្នាក់ងារអនុវត្តគម្រោង (Implement Agency) ។

គម្រោងគ្របដណ្តប់លើខេត្តគោលដៅចំនួន៤ គឺខេត្ត តាកែវ កំពត កំពង់ចាម និងត្បូងឃ្មុំ ។ ការងារអនុវត្តគម្រោងបានចំណាយពេលវេលាអស់៦០% រីឯការចំណាយថវិកាអស់ (Cumulative to date Expenditures) ២៣,០៦១,១២៣ ដុល្លារអាមេរិក ស្មើនិង១៦,៤%ប្រៀបធៀបទៅនិងគម្រោងទាំមូល។ សរុបការងាររីកចំរើនជារួមគិតត្រឹមខែ កក្កដា ឆ្នាំ២០២៣ ស្មើនិង៤៨,៨២%។

## II. សកម្មភាពការងារនិងលទ្ធផលសម្រេចបាន

### សមាសភាគទី១៖ កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវាក់ផលតកម្មកសិកម្ម អោយមានភាពប្រសើរឡើងហើយដែលធន់នឹងការបម្រែបម្រួលអាកាសធាតុ។

- **ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័នសម្រាប់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖**
    - ការងារសាងសង់ឃ្លាំងសហគមន៍ (Agriculture Cooperative storage) ឃ្លាំងសហគមន៍ ចំនួន៥៥ឃ្លាំង បានបញ្ចប់១០០% រីឯ២៥ឃ្លាំងការងារសាងសង់សំរេចបាន៥៤,៦៥% ។
    - ការងារសាងសង់កែលម្អមន្ទីរពិសោធន៍ជាតិ (National Laboratory GDA) បានបញ្ចប់១០០%
    - ការងារសាងសង់ផ្ទះសំណាញ់ (Green House) បានបញ្ចប់១០០%
    - ការងារសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាល (PADC) ៣ខេត្តបានបញ្ចប់១០០% (តាកែវ កំពង់ចាម និងត្បូងឃ្មុំ)
    - ការងារសាងសង់រោងជាងជួសជុលគ្រឿងយន្តកសិកម្ម (MEW) ៣ខេត្តបានបញ្ចប់១០០% ( កំពត កំពង់ចាម និងត្បូងឃ្មុំ)
    - ការងារសាងសង់ឡជីវឧស្ម័នបង្ហាញ (Bio-digester) បាន៥៦ឡ ក្នុងចំណោម៤ខេត្ត (តាកែវ កំពត កំពង់ចាម និងត្បូងឃ្មុំ)

- ការងារសាងសង់រោងជីកំប៉ុស្តិ៍បង្ហាញ(Compost-Hut) បាន22រោង ក្នុងចំណោម៤ខេត្ត (តាកែវ កំពត កំពង់ចាម និងត្បូងឃ្មុំ)

❖ **ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័នសម្រាប់ ក្រសួងធនធានទឹក និងឧតុនិយមៈ**

- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រត្រពាំងរុនក្នុងខេត្តកំពត បានបញ្ចប់១០០% ដែលមានផ្ទៃដីស្រោចស្រព១០០ហិកតា
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រតាកុចក្នុងខេត្តកំពត ការងារសាងសង់សំរេចបាន៩៩% ដែលមានផ្ទៃដីស្រោចស្រព៤០០ហិកតា។
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រក្រាំងអំពិលក្នុងខេត្តតាកែវ បានបញ្ចប់១០០% ដែលមានផ្ទៃដីស្រោចស្រព២០០ហិកតា
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រព្រៃក្តួចក្នុងខេត្តតាកែវ បានបញ្ចប់១០០% ដែលមានផ្ទៃដីស្រោចស្រព៥៥០ហិកតា
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រក្បាលទឹកក្នុងខេត្តត្បូងឃ្មុំ បានបញ្ចប់១០០% ដែលមានផ្ទៃដីស្រោចស្រព២៥០ហិកតា
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រទួលព្រីងក្នុងខេត្តត្បូងឃ្មុំ បានបញ្ចប់១០០% ដែលមានផ្ទៃដីស្រោចស្រព១០០ហិកតា
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រត្រពាំងគ្រោះក្នុងខេត្តត្បូងឃ្មុំ បានបញ្ចប់៩៨% ដែលមានផ្ទៃដីស្រោចស្រព១០០ហិកតា
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រប្រាំកុម្ភៈក្នុងខេត្តកំពង់ចាម ការងារសាងសង់សំរេចបាន៨០% ដែលមានផ្ទៃដីស្រោចស្រព៩៥០ហិកតា ។
- ការងារសាងសង់ប្រព័ន្ធធារាសាស្ត្រអូរកំប្រុកក្នុងខេត្តកំពង់ចាម ការងារសាងសង់សំរេចបាន៨០% ដែលមានផ្ទៃដីស្រោចស្រព៣៥០ហិកតា ។

❖ **ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័នសម្រាប់ ក្រសួងអភិវឌ្ឍន៍ជនបទ៖**

- ការងារសាងសង់ផ្លូវលំជនបទដោយក្រាលកៅស៊ូពីរជាន់ (Double Bitumen Surface Treatment) ក្នុងខេត្តកំពត ការងារសាងសង់សំរេចបាន ៥៤% (Lot 1) និង ៧១% (Lot 2) ដែលមានប្រវែង២០,០៥ គីឡូម៉ែត្រ ។
- ការងារសាងសង់ផ្លូវលំជនបទដោយក្រាលកៅស៊ូពីរជាន់(Double Bitumen Surface Treatment) ក្នុងខេត្តតាកែវ ការងារសាងសង់សំរេចបាន ៩៤% (Lot 1) និង ៩៣% (Lot 2) ដែលមានប្រវែង១៤,៦៧ គីឡូម៉ែត្រ ។
- ការងារសាងសង់ផ្លូវលំជនបទដោយក្រាលកៅស៊ូពីរជាន់(Double Bitumen Surface Treatment) ក្នុងខេត្តកំពង់ចាម ការងារសាងសង់សំរេចបាន ៦៤% (Lot 1) និង ៥៤% (Lot 2) ដែលមានប្រវែង១៤,៦០ គីឡូម៉ែត្រ ។

- ការងារសាងសង់ផ្លូវលំជនបទដោយក្រាលកៅស៊ូពីរជាន់(Double Bitumen Surface Treatment) ក្នុងខេត្តត្បូងឃ្មុំ ការងារសាងសង់សំរេចបាន ៨១% (Lot 1) និង ៧0% (Lot 2) ដែលមានប្រវែង២១,៧៧ គីឡូម៉ែត្រ ។

## សមាសភាគទី ២៖ ការជំរុញការអនុវត្តន៍កសិកម្មល្អ និងកសិ-ធុរៈកិច្ចមានលក្ខណៈស្របទៅនឹងបម្រែបម្រួលអាកាសធាតុ

(១) បញ្ចេញពូជដែលធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ

សកម្មភាព៖ ការបង្កើតអោយមានពូជដែលធន់នឹងការប្រែប្រួលអាកាសធាតុ

- ពូជស្រូវចំនួនពីរ ដែលមានឈ្មោះថា ផ្កាមាលតី (PMD) និង CAR-16 និងពូជពោតសដំណើបមួយប្រភេទ ដែលមានឈ្មោះថា CM1 ត្រូវបានចេញផ្សាយមុនគម្រោងចាប់ផ្តើម ហើយនៅឆ្នាំ 2022 CARDI បានធ្វើការបង្ហាញនៅតាមខេត្តគោលដៅ។ បច្ចុប្បន្ន CARDI កំពុងអភិវឌ្ឍពូជស្រូវដើម្បីទទួលបានទិន្នផលខ្ពស់ គុណភាពគ្រាប់ធញ្ញជាតិល្អ និងធន់នឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពជាបន្តបន្ទាប់រួមមាន ការធ្វើទំនើបកម្មនៅក្នុង CARDI និងការសាកល្បងច្រើនទីតាំងដោយសហការជាមួយបុគ្គលិក PDAFF ។
- ពូជស្រូវមួយប្រភេទ ឈ្មោះ ចំប៉ីស70 ត្រូវបានចេញផ្សាយនៅឆ្នាំ 2023 សម្រាប់ការធ្វើបង្ហាញរបស់កសិករនៅក្នុងគម្រោង CFAVC (គ្រាប់ពូជសុទ្ធគ្រឹះពី CARDI)។
- កសិករចំនួន 50 នាក់ (23 នាក់ជាស្រី = 46%) បានទទួលការបណ្តុះបណ្តាល ក្នុងការបណ្តុះបណ្តាលក្រុមកសិករស្តីពីការអនុវត្តន៍ការងារគ្រប់គ្រងល្អបំផុត (BMP) ។(វឌ្ឍនភាព ក្នុងខែមិថុនា២០២៣)
- កសិករចំនួន 1350 នាក់ (642 នាក់ជាស្រី = 47%) បានទទួលការបណ្តុះបណ្តាល ក្នុងការបណ្តុះបណ្តាលក្រុមកសិករស្តីពីការអនុវត្តន៍ការងារគ្រប់គ្រងល្អបំផុត (BMP) និងបច្ចេកទេសផលិតពូជស្រូវ និងចុះតាមដាន(RSPT/FU) ។(ការបូកយោងតាំងពីគម្រោងចាប់ផ្តើម២០១៩ មកដល់ពេលនេះ)
- បានធ្វើការចុះត្រួតពិនិត្យលើការបង្កាត់ពូជស្រូវនៅខេត្តគោលដៅចំនួន៤ មានដូចជា៖ ខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ និងកំពតជាមួយនឹង IA-CARDI និង PPIUsដើម្បីតាមដានវឌ្ឍនៈភាពនៃការបង្ហាញពូជស្រូវ
- ផ្តល់គ្រាប់ពូជស្រូវសុទ្ធគ្រឹះសម្រាប់បង្ហាញ=855kg (TAK=110kg, KPT=490kg, និង ខេត្ត TBK =255kg)។(វឌ្ឍនភាព ក្នុងខែមិថុនា២០២៣)
- ផ្តល់គ្រាប់ពូជស្រូវសុទ្ធគ្រឹះសម្រាប់បង្ហាញ=855kg (TAK=110kg, KPT=490kg, និង ខេត្ត TBK =255kg)។(វឌ្ឍនភាព ក្នុងខែមិថុនា២០២៣)។(ការបូកយោងតាំងពីគម្រោងចាប់ផ្តើម២០១៩ មកដល់ពេលនេះ)

(២) ការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តន៍ផលិតកម្មភាគរៈបរិស្ថាននិងបច្ចេកវិទ្យា

សកម្មភាព៖ ការពង្រឹងសមត្ថភាពដោយភាគរៈបរិស្ថាន

- កសិករចំនួន 12,699 នាក់ (ស្រ្តីមានចំនួន 6,028 នាក់ = 47%) បានទទួលការបណ្តុះបណ្តាលលើកសិកម្មវៃឆ្លាត (Climate Smart Agriculture-CSA), ផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព (Sustainable Rice Platform-SRP), ការអនុវត្តដំណាំល្អនៅកម្ពុជា (CamGAP), ការបណ្តុះបណ្តាលក្រុមប្រឹក្សាភិបាលនៃសហគមន៏កសិកម្ម (Agriculture Cooperatives-ACs) ស្តីពីការអភិវឌ្ឍន៍អាជីវកម្ម និងការបណ្តុះបណ្តាលលើការស្តារគុណភាពផ្ទៃដី (យន្តការកសិកម្ម)។
- សិក្ខាសាលាផ្សព្វផ្សាយស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា
- កំណត់បាននូវប្រព័ន្ធធារាសាស្រ្តចំនួន 05 សម្រាប់លទ្ធភាពនៃការធ្វើការកៀរពង្រាបដីដោយប្រពន្ធ័កាំរស្មីឡាស៊ែរ ក្នុងតំបន់គម្រោង ដែលមាន 2ប្រពន្ធ័នៅតាកែវ, 1ប្រពន្ធ័នៅខេត្តកំពត, 1ប្រពន្ធ័នៅខេត្តត្បូងឃ្មុំ, 1 ប្រពន្ធ័នៅខេត្តកំពង់ចាម ដែលមានផ្ទៃដីចំនួន 418.58 ហិចតា ត្រូវបានវាយតម្លៃនិងការធ្វើផែនទី។ ឯកសារដេញថ្លៃកំពុងត្រូវបានរៀបចំដោយ CS1 និងដោយមានការពិគ្រោះយោបល់ជាមួយ CS2 និងអង្គភាពលទ្ធកម្មនៃ PMU ។
- សង្ខេបវឌ្ឍនភាពនៃការជ្រើសរើសពូជស្រូវសម្រាប់ពង្រាបដីត្រឹមខែមករាដល់ខែធ្នូ ឆ្នាំ២០២២៖
    - តាកែវ: 125.89Ha with 935HHs (397F)
    - កំពត: 67.99Ha with 467HHs (260F)
    - កំពង់ចាម: 166.40Ha with 730HHs (258F)
    - ត្បូងឃ្មុំ: 58.30Ha ជាមួយ 646HHs (302F)
    - សរុប៖ 418.58 Ha with 2,778HHs (1,227F)
- ការបង្ហាញពូជស្រូវសុទ្ធគ្រើះ (2020-2023) :
    - ការបង្ហាញពូជស្រូវ (2020-2023)
        - ឈ្មោះគ្រាប់ពូជ៖ ផ្ការំដួល (PRD), ផ្កាមាលតី(PMD),CAR16 និងចំប៉ីស៧0 (គ្រាប់ពូជសុទ្ធគ្រើះពី CARDI)
        - ចំនួនបង្ហាញកសិករ៖ 298នាក់ ក្នុងនោះស្រី142នាក់
        - ផ្ទៃដី៖ 95.54 ហិកតា
        - ទិន្នផលជាមធ្យម 3.98តោន/ហិកតា (គិតឆ្នាំ២០២០-២០២២)
        - ចំនួនគ្រាប់ពូជផលិតបាន 262.497 គីឡូក្រាម(គិតឆ្នាំ២០២០-២០២២)
        - ចំនួនគ្រាប់ពូជចែកចាយដល់សហគមន៍៖ ៩៤.៦៨២ គីឡូក្រាម(គិតឆ្នាំ២០២០-២០២២)
        - ចំនួនគ្រាប់ពូជគ្រើះផ្តល់ដល់កសិករសំខាន់ៗ(គ្រាប់ពូជសុទ្ធគ្រើះយកពីCARDI) ៖៤,១២៥គីឡូក្រាម305kg (គ្រាប់ពូជផ្ការំដួល(PRD) = ២,៥១៥kg,គ្រាប់ពូជផ្កាមាលតី(PMD)= ៩៩0 គីឡូក្រាម, គ្រាប់ពូជចំប៉ីស៧0= ១0៥ គីឡូក្រាម និង CAR16 = 80kg)

- ការបង្ហាញអំពីការផលិតពូជដំឡូងមី (២០២១-២០២៣)

- ឈ្មោះពូជ: 81, Rayong9, Hauybong60, KU50, (ពីស្ថានីយ៍ចំការលើ)
- ការបង្ហាញអំពីកសិករ៖ 52នាក់ ស្រី27នាក់
- ផ្ទៃដី៖ 52 ហិកតា
- ទិន្នផលជាមធ្យម 31.5 តោន/ហិកតា(តែឆ្នាំ២០២១-២០២២)
- ចំនួនបាច់នៃការផ្តល់ពូជដំឡូងមីដល់សហគមន៍៖ 15,600 បាច់ (ពូជ 81=11,250bundles and Rayon9=3000 bundles, KU50=225 bundles and Huybon60=1,125 bundles)

- ការផលិតបង្កាត់ពូជពោត (២០២២-២០២៣)
  - ឈ្មោះគ្រាប់ពូជ៖ CHM01 និង CM1 (CHM01 ពីស្ថានីយ៍បន្ទាយដែក/GDA និង គ្រាប់ពូជ CM1 ពី CARDI)
  - ការបង្ហាញកសិករ៖ 45នាក់ ស្រី21 នាក់(ក្នុងឆ្នាំ២០២២)
  - ផ្ទៃដី៖ 22.5 ហិកតា(ក្នុងឆ្នាំ២០២២)
  - ទិន្នផលជាមធ្យម 5.12តោន/ហិកតា (ក្នុងឆ្នាំ២០២២)
  - កសិករជាច្រើនចាប់អារម្មណ៍ និងត្រូវការគ្រាប់ពូជ (CHM01) សំរាប់សហគមន៍របស់ពួកគេ
- ការរៀបចំ និងការបង្កើតសហគមន៏កសិករប្រើប្រាស់ទឹក (FWUCS of FWUGS)
  - 12 សហគមន៏កសិករប្រើប្រាស់ទឹកត្រូវបានបង្កើត 100%;
  - សហគមន៏កសិករប្រើប្រាស់ទឹកកំពុងដំណើរការបង្កើត (ត្រពាំងបឹងនិងកណ្តោលនៅខេត្តកំពតសម្រេចបាន៨៨%, ព្រៃរំដេងនៅខេត្តតាកែវសម្រេចបាន៨០% និងត្បូងដារីនិងកំពង់រាំងនៅខេត្តត្បូងឃ្មុំសម្រេចបាន ៧៥%)
  - វគ្គបណ្តុះបណ្តាលចំនួន 106 វគ្គ ត្រូវបានផ្តល់ជូនអ្នកតំណាង FWUCs/FWUGs ចំនួន 4,135 នាក់ និងអាជ្ញាធរមូលដ្ឋានដែលក្នុងនោះ 1,097 នាក់ជាស្ត្រី។

(៣) លើកកម្ពស់គ្រឿងយន្តកសិកម្មនិងការផ្សព្វផ្សាយ

សកម្មភាព៖ ជុំរុញ និងផ្សព្វផ្សាយការប្រើប្រាស់គ្រឿងយន្តបនីយ៍កម្មកសិកម្ម

- អាគារបណ្តុះបណ្តាល (Provincial Agricultural Development Centers) ចំនួនបីត្រូវបានសាងសង់រួចរាល់១០០% នៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងតាកែវ ។ ចំណែកនៅខេត្តកំពតកំពង់ដំណើរការលទ្ធកម្ម។
- អាគាររោងជាង (Provincial Agricultural Engineering Workshops) ចំនួនបី ត្រូវបានសាងសង់រួចរាល់១០០% នៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងកំពត។ ចំណែកនៅខេត្តតាកែវកំពង់ដំណើរការលទ្ធកម្ម។

## សមាសភាគទី៣៖ ការរៀបចំឲ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគកសិ-ធុរៈកិច្ចប្រកបដោយភារៈបរិស្ថាន

១) ការអភិវឌ្ឍន៍គោលនយោបាយកសិធុរៈកិច្ច និងស្តង់ដា

- ការអភិវឌ្ឍន៍នៃការបង្កើតក្រុមអ្នកផលិត គោលការណ៍ណែនាំដែលភ្ជាប់ជាមួយវិស័យឯកជនទៅកាន់ទីផ្សារៈ បានបញ្ចប់ (ការកែសម្រួលសេចក្តីព្រាងទី 4) ដើម្បីសម្រេចបាននូវក្រុមអាជីវកម្ម កសិ-ពាណិជ្ជកម្ម កសិកម្មតាមកិច្ចសន្យា។
- ការរៀបចំចងក្រងសៀវភៅណែនាំស្តង់ដារ CAMGAP ផ្លែឈើនៃតំបន់ត្រូពិចសម្រាប់ផ្លែស្វាយត្រូវបានបង្កើតឡើង ដោយមានការចូលរួមពីនាយកដ្ឋានពាក់ព័ន្ធ រៀបចំបាន50% (IA-GDA)។
- ការរៀបចំចងក្រងសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) សម្រាប់ការធ្វើតេស្តគុណភាពជីជីវៈ បានបញ្ចប់ការកែសម្រួលសេចក្តីព្រាងលើកទី 3 ។
- ការរៀបចំចងក្រងសៀវភៅណែនាំនៃនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) សម្រាប់ការធ្វើតេស្តគុណភាពជីសរីរាង្គ ការអភិវឌ្ឍន៍គោលការណ៍ណែនាំ និងនីតិវិធីបច្ចេកទេសសម្រាប់មន្ទីរពិសោធន៍ ISO17025 ។ ការទទួលស្គាល់ត្រូវបានបញ្ចប់ ការកែប្រែសេចក្តីព្រាងទី 3។
- ការរៀបចំចងក្រងសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) សម្រាប់ការធ្វើតេស្តគុណភាពជីសរីរាង្គគឺនៅក្នុងកំណែព្រាងដំបូង។
- ការរៀបចំចងក្រងសៀវភៅណែនាំស្តីពីការដាំដុះជាលិកាដំឡូងមីត្រូវបានបញ្ចប់នៅក្នុងការកែសម្រួលសេចក្តីព្រាងទី 4
- បន្តការងារបញ្ច្រាបផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០: បន្តសហការ និងអនុវត្តផ្សព្វផ្សាយជាមួយភ្នាក់ងារអនុវត្តគម្រោង និងនាយកដ្ឋានជំនាញ ស្របតាមផែនការឆ្នាំ ២០២៣។
- បន្តការងារបញ្ច្រាបគោលនយោបាយឡជីវៈឧស្ម័ន នៅកម្ពុជា ២០២១-២០៣០: បន្តសហការណ៍ និងអនុវត្តការផ្សព្វផ្សាយ និងធ្វើសមាហរណកម្មក្នុងសកម្មភាពគម្រោង ជាមួយភ្នាក់ងារអនុវត្តគម្រោង និងនាយកដ្ឋានជំនាញ នៃផែនការឆ្នាំ២០២៣។
- បន្តការងារតាមដាននៃការរៀបចំឯកសារស្តង់ដារបច្ចេកទេសសម្រាប់ការវិភាគគុណភាពជីសរីរាង្គ (SOP)
- បន្តការងាររៀបចំសៀវភៅមគ្គុទេសក៍ណែនាំបច្ចេកទេសនិងដំណើរការទទួលស្គាល់គុណភាពមន្ទីរពិសោធន៍តាមស្តង់ដារ ISO17025 និងពិនិត្យការបញ្ចប់ការពង្រាងលើកទី៣។
- បន្តការងាររៀបចំបទដ្ឋានស្តង់ដារបច្ចេកទេសសម្រាប់ការវិភាគគុណភាព ជីកសិកម្មជីវសាស្ត្រ (SOP) និងពិនិត្យការបញ្ចប់ការពង្រាងលើកទី៣។
- បន្តការងាររៀបចំវិធីសាស្ត្រអនុវត្តជាលិកាវប្បកម្មដំណាំដំឡូងមី និងពិនិត្យការបញ្ចប់សេចក្តីព្រាងលើកទី៤
- បន្តការងារពិនិត្យ និងបញ្ចប់ពង្រាងពីការរៀបចំគោលការណ៍ណែនាំ ស្តីពីការបង្កើតក្រុមផលិត

២ ) សកម្មភាព៖ ការលើកកម្ពស់ហិរញ្ញប្បទានបៃតង និងយន្តការចែករំលែកពីហានិភ័យ

- កំណត់អត្តសញ្ញាណ៖ 50 ធនាគារ/MFI
  - បានបញ្ចប់ការងារប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល១០០%
  - ផែនការអភិវឌ្ឍន៍បណ្តុះបណ្តាល៖ កំពុងបន្ត ៨០%
  - ការអភិវឌ្ឍន៍សម្ភារៈបណ្តុះបណ្តាល៖ កំពុងបន្ត 70%
  - បើកវគ្គបណ្តុះបណ្តាលចំនួនពីរជាមួយអេស៊ីលីដា និង ធនាគារអេអឌីប៊ី

- ការរៀបចំចងក្រងរបាយការណ៍ហិរញ្ញវត្ថុបៃតង៖ បានបញ្ចប់ និងព្រាង។
- ការពិគ្រោះយោបល់ថ្នាក់ជាតិលើរបាយការណ៍៖ សេចក្ដីព្រាងកំណត់ចំណាំបានបញ្ចប់។
- បានចូលរួមរៀបចំបង្កើតទីតាំងផ្ដល់ហិរញ្ញប្បទានបៃតង (MOE/ARDB/NBC/Mekong Strategy Partners មានការរីកចម្រើន) ហើយរង់ចាំការពិនិត្យឡើងវិញ និងការអនុម័តរបស់ GCF ។
- ការប្រឹក្សាយោបល់លើការផ្ដល់ហិរញ្ញប្បទានបៃតងជាមួយ ARDB និង អេស៊ីលីដា។
- បុគ្គលិកចំនួន 16 នាក់មកពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ARDB បានទទួលការបណ្ដុះបណ្ដាលផ្នែក CSA និងហិរញ្ញវត្ថុបៃតង។

- កំណត់អត្តសញ្ញាណ៖ 30 ACs/ Agribusiness
  - បានបញ្ចប់ការងារប៉ាន់ប្រមាណតម្រូវការបណ្ដុះបណ្ដាល១០០%
  - រៀបចំចងក្រងសម្ភារៈបណ្ដុះបណ្ដាល៖ កំពុងធ្វើបន្ត 70%
  - រៀបចំចងក្រងសម្ភារៈបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុ
  - បានបើកវគ្គបណ្ដុះបណ្ដាល កសិធុរៈកិច្ច៖ ចំនួ27វគ្គ (អ្នកចូលរួមសរុប: 389 F: 174)
  - បានបើកវគ្គបណ្ដុះបណ្ដាលចំនួន 2 ស្ដីពីការប្រែប្រួលអាកាសធាតុ ហិរញ្ញប្បទានបៃតង និងកសិកម្មវៃឆ្លាត ដល់សិក្ខាកាមចំនួន 65 នាក់ ក្នុងនោះមានស្ត្រីចំនួន 17 នាក់សម្រាប់ PPIUs ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទ(ARDB) និង ACs នៅក្នុងខេត្តចំនួន៤។
- បានកំណត់អត្តសញ្ញាណ ក្រុមហ៊ុនធានារ៉ាប់រងដំណាំ និងកម្ចីបៃតង៖ រួមមាន (ហ្វតតេសម្រាប់ការធានារ៉ាប់រងដំណាំ អេស៊ីលីដា/អេឌីប៊ី សម្រាប់គម្រោងកម្ចីបៃតង)
  - រៀបចំចងក្រងសម្ភារៈសំរាប់វគ្គបណ្ដុះបណ្ដាល បាន60%
  - បានចូលរួមក្នុងពិធីចុះកិច្ចព្រមព្រៀងស្ដីពីការចែករំលែកទិន្នន័យជាមួយក្រុមហ៊ុន Forte លើការធានារ៉ាប់រងដំណាំ។
  - វេទិកាផ្ដោតសំខាន់លើដំណាំស្រូវ ដំឡូងមី ពោត ស្វាយ និងដំណាំជាក់លាក់ផ្សេងទៀត៖ វគ្គបណ្ដុះបណ្ដាលចំនួន 5 ដែលធ្វើឡើងដោយមានអ្នកចូលរួមសរុប 199 នាក់ (28F)។
  - វេទិកាធុរកិច្ចស្ដីអំពីស្រូវ ដំឡូងមី និងទំនិញកសិផលជាក់លាក់ផ្សេងទៀត (ជាមួយអ្នកផ្គត់ផ្គង់បញ្ចូល អ្នកផលិត អាជីវករ/អ្នកទិញ ឬអ្នកប្រមូលទិញ)៖ វគ្គបណ្ដុះបណ្ដាលចំនួន 3 ដែលធ្វើឡើងជាមួយអ្នកចូលរួម 80 (11F)។
  - វេទិកាពិគ្រោះយោបល់ស្ដីពីកិច្ចសន្យាកសិកម្មស្របច្បាប់នៅថ្នាក់ខេត្ត៖ បានធ្វើវេទិកាពិគ្រោះយោបល់ចំនួន 4 ជាមួយអ្នកចូលរួម 81 (16F) ។
  - បានជួបប្រជុំជាមួយមន្ត្រីឥណទាននៃធនាគារអេស៊ីលីដា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត នៅខេត្តកំពង់ចាម និងខេត្តកំពត ដើម្បីកំណត់ពីសមត្ថភាពវាយតម្លៃតម្រូវការលើការផ្ដល់ហិរញ្ញប្បទានបៃតង និងការត្រៀមខ្លួនរបស់ស្ថាប័នក្នុងការអនុវត្តការផ្ដល់ហិរញ្ញប្បទានបៃតង។ ជាលទ្ធផល ទាំង អេស៊ីលីដា

និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត មិនបានដឹងអំពីគោលគំនិតនៃគម្រោងបៃតងនេះទេប៉ុន្តែពួកគេប្តេជ្ញាអនុវត្តប្រសិនបើមានតម្រូវការរបស់ធនាគារជាតិ។រៀបចំសម្ភារៈបណ្តុះបណ្តាលដោយពិភាក្សាជាមួយទីប្រឹក្សាអន្តរជាតិ ដើម្បីផ្តល់ជូនដល់អង្គភាពអនុវត្តគម្រោង ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

- បានចូលរួមកិច្ចប្រជុំជាមួយសមាគមធនាគារកម្ពុជា ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាលសម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃ។ ជាលទ្ធផល ការ  បណ្តុះបណ្តាល ស្តីពីការប្រែប្រួលអាកាសធាតុលើគោលគំនិត ការបន្សុំា ការកាត់បន្ថយ និងអព្យាក្រឹតភាពនៃកាបូន គឺជាអាទិភាពចម្បង និងជាអាទិភាពសម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆ្ពោះទៅរកការយល់ដឹងយ៉ាងល្អអំពីការផ្តល់ហិរញ្ញប្បទានបៃតង។
- បានរៀបចំការប្រជុំតម្រង់ទិសជាមួយសមាជិកសហគមន៍កសិម្ម មានអ្នកចូលរួមចំនួន ៥៦នាក់ (ស្រី ៣២នាក់) នៅសហគមន៍កសិកម្ម រស្មីសាមគ្គីអមតៈ និងខ្ពបរុនគំនិតថ្មី (AC) ខេត្តកំពត និងលើការវាយតម្លៃហិរញ្ញប្បទានបៃតង និងការអភិវឌ្ឍន៍គម្រោងបៃតង និងភ្ជាប់ទៅអេស៊ីលីដា និង ARDB។
- បានរៀបចំការប្រជុំតម្រង់ទិស ស្តីពីបម្រែបម្រួលអាកាសធាតុ និងហិរញ្ញប្បទានបៃតង និងបានណែនាំដល់ AC នៅត្រពាំងស្រងែ និងកំពែងសែនសុខសំបូរ នៅខេត្តតាកែវ ដែលមានអ្នកចូលរួមចំនួន ៤៦ នាក់ ក្នុងនោះមានស្ត្រី ២៤ នាក់។
- បានរៀបចំការប្រជុំតម្រង់ទិសជាមួយសមាជិកសហគមន៍កសិម្ម មានអ្នកចូលរួមចំនួន ៣៧នាក់ (ស្រី ១៨នាក់) នៅសហគមន៍ក្តីសង្ឃឹមកសិករ និងសាមគ្គីកក់ នៅខេត្តត្បូងឃ្មុំ ស្តីពីការអភិវឌ្ឍន៍គម្រោងបៃតង និងជម្រើស  បន្សុំានឹងការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោង។
- ប្រជុំជាមួយការធានារ៉ាប់រងដំណាំ  ដើម្បីរៀបចំការផ្សព្វផ្សាយស្តីពីការព្យាករណ៍អាកាសធាតុ  និងការធានារ៉ាប់រងដំណាំនៅខេត្តគោលដៅ។
- បានរៀបចំការប្រជុំតម្រង់ទិស ស្តីពីការផ្តល់ហិរញ្ញប្បទានបៃតង និងគម្រោងបៃតងដល់ PPIU មកពីខេត្តចំនួនបួន ដែលមានអ្នកចូលរួមចំនួន ២៥នាក់/ស្ត្រី ៤នាក់។
- ការផ្តួចផ្តើមគំនិតភាពជាដៃគូរវាងស្ថាប័នសាធារណៈ  និងវិស័យឯកជនសម្រាប់បរិយាកាសកសិ-ធុរៈកិច្ច បានបន្តការតាមដាននៃការរៀបចំគោលការណ៍ណែនាំ ស្តីពីការបង្កើតក្រុមផលិត។

- ទីប្រឹក្សា ICT ទើបតែត្រូវបានប្រមូលផ្តុំនៅក្នុងខែមករា ឆ្នាំ 2023 ហើយសិក្ខាសាលាចាប់ផ្តើមនឹងធ្វើឡើងនៅថ្ងៃទី 6 ខែមេសា ឆ្នាំ 2023។
  - បានរៀបចំរបាយការណ៍ចាប់ផ្តើមអនុវត្តគម្រោង(Inception report)
  - បានរៀបចំសិក្ខាសាលាស្តីពីការចាប់ផ្តើមតំណើរការអនុវត្ត  គម្រោងនៅថ្នាក់ជាតិ (Inception workshop)
  - រៀបចំអភិវឌ្ឍតម្រូវការរបស់ប្រព័ន្ធ និងរបាយការណ៍ស្ថាបត្យកម្មបច្ចេកវិទ្យា
  - ការរៀបចំសម្រាប់កម្មវិធីសាកល្បងសម្រាប់កសិកម្មវៃឆ្លាតដែលធន់និងបម្រែមប្រួលអាកាសធាតុ

## ការគ្រប់គ្រង ការងារហិរញ្ញវត្ថុ និងលទ្ធកម្មគម្រោង

### *ក. លទ្ធផលការងារហិរញ្ញវត្ថុ*

- ការចំណាយទូទៅរបស់ គម្រោងទាំងមូលគិតត្រឹម ខែមិថុនា ឆ្នាំ២០២៣ សរុបគិតតាមប្រភពថវិកា៖
    - ថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ADB Loan 3661 CAM(COL) ចំណាយអស់ ២០,៧៦៨,០៥២ លានដុល្លាអាមេរិក
    - ថវិកាកម្ចីពីមូលនិធិអាកាធាតុបែបង ADB Loan 8346(GCF) ចំណាយអស់ ១,៣២២,០៤៩ លានដុល្លាអាមេរិក
    - ថវិកាជំនួយឥតសំណងពីមូលនិធិអាកាធាតុបៃបង ADB Grant 0579(GCF) ចំណាយអស់ ៣,៦៨០,២៨១ លានដុល្លាអាមេរិក
    - ថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា (Cambodia Government) ចំណាយអស់ ៨២៧,៥៨៧ ដុល្លាអាមេរិក
    - ថវិកាបដិភាគពីអ្នកទទួលផល (Beneficiaries' Contribution) ចំណាយអស់ 00 ដុល្លាអាមេរិក

- សរុបសម្រាប់ចំណាយ ១ដល់5 មានចំនួន២៦, ៥៩៧, ៩៧០.០០ លានដុល្លារ ស្មើនឹង១៨.៩% ធៀបនិងថវិកាសរុប ១៤១, ០៤០, ០០០.០០លានដុល្លាអាមេរិក។

### *ខ.លទ្ធផលការងារលទ្ធកម្ម*

#### ខ.១ លទ្ធផលការងារលទ្ធកម្មតាមផែនការលទ្ធកម្ម១៨ខែ

- **លទ្ធកម្មទំនិញ**

- រៀបចំឯកសារដេញថ្លៃស្តីពីការផ្គត់ផ្គង់សារធាតុគីមី (ប្រតិករ) (G1.a) សំរាប់ប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ជាតិកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម។
- រៀបចំឯកសារដេញថ្លៃស្តីពីការផ្គត់ផ្គង់សម្ភារៈសំរាប់រោងជាងជួសជុលគ្រឿយន្តកសិកម្ម (G4) សំរាប់ប្រើប្រាស់ក្នុងមន្ទីរកសិកម្មតាមខេត្តគោលដៅទាំង៤។
- រៀបចំឯកសារដេញថ្លៃស្តីពីការផ្គត់ផ្គង់សម្ភារៈសំរាប់ឡសម្ងួត (G16) សំរាប់ប្រើប្រាស់ក្នុងឃ្លាំងស្តុករបស់សគមន៍កសិកម្មតាមខេត្តគោលដៅទាំង៤។
- រៀបចំឯកសារដេញថ្លៃស្តីពីការផ្គត់ផ្គង់សម្ភារៈសំរាប់ប្រើប្រាស់ក្នុងផ្នែក ICT (G7)មន្ទីរកសិកម្មខេត្តកំពង់ចាម
- រៀបចំឯកសារដេញថ្លៃស្តីពីការផ្គត់ផ្គង់ម៉ាស៊ីនកិនស្រូវខ្នាតតូចសំរាប់សគមន៍កសិកម្ម (G8) តាមខេត្តគោលដៅទាំង៤

- **លទ្ធកម្មការងារ**

- បានបញ្ចប់ការរៀបចំឯកសារដេញថ្លៃស្តីពីការងារកៀពង្រាបដីស្រែដោយបច្ចេកវិទ្យាប្រព័ន្ធឡាស៊ែ (Laser land leveling) និងបានដាក់ជូនADB ស្នើសុំការយល់ព្រម កាលពីថ្ងៃទី២៦ មិថុនា ឆ្នាំ២០២៣។

- រៀបចំកែសម្រួលផែនការលទ្ធកម្ម ដោយមានបន្ថែមកាងរងារសាង់ឃ្លាំងចំនួន៦ នៅក្នុងខេត្តតាកែវ និងកំពត ការងារសាងសង់អាគារបណ្ដុះបណ្ដាល(PADC)ចំនួន១ នៅក្នុងខេត្តកំពត អាគាររោងជាង(MEW)ចំនួន១ នៅក្នុងខេត្តតាកែវ ដើម្បីដាក់ជូនADBស្នើសុំការឯកភាព។
    - **លទ្ធកម្មសេវា**
- បាននឹងកំពុងរៀបចំការវាយតម្លៃស្នើសុំផ្លាស់ប្ដូរទីប្រឹក្សាផ្នែក យេនឌ័រ (Gender) និងសុវត្ថិភាពសង្គម (Social safeguard Specialist) សំរាប់ហ៊ុនទីប្រឹក្សា CS1.

## III. ទិសដៅការងារអនុវត្តបន្ត

### ក. ការងារសម្រាប់ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ៖

- បន្តការពិនិត្យឡើងវិញ និងប្រជុំជាមួយ អង្គភាពគ្រប់គ្រងគម្រោង, នាយកដ្ឋានជំនាញដែលពាក់ព័ន្ធផ្សេងៗ, ភ្នាក់ងារអនុវត្តគម្រោង និងអង្គភាពអនុវត្តគម្រោងតាមខេត្តគោលដៅស្តីពីការពិនិត្យលើការអនុវត្តផែនការ។
- បន្តការតាមដាន និងត្រួតពនិនិត្យសកម្មភាព ដែលអនុវត្តដោយ អង្គភាពអនុវត្តគម្រោងតាមខេត្តគោលដៅ។
- រៀបចំតារាងសកម្មភាពការងារ ដោយសហការជាមួយ អង្គភាពគ្រប់គ្រងគម្រោង, នាយកដ្ឋានជំនាញដែលពាក់ព័ន្ធផ្សេងៗ, ភ្នាក់ងារអនុវត្តគម្រោង និងអង្គភាពអនុវត្តគម្រោងតាមខេត្តគោលដៅ។
- រៀបចំផែនការសកម្មភាពលើវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាផ្សេងៗ។
- រៀបចំឯកសារដេញថ្លៃស្ដីពីការផ្គត់ផ្គង់សម្ភារៈធ្វើតេស្តរហ័ស (G2) សំរាប់ធ្វើតេស្តជីសរីរាង្គកសិកម្ម និងជីជីវសាស្រ្តកសិកម្មសំរាប់ប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ជាតិកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម។
- បន្តការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលនៅសេសសល់ពីត្រីមាសមុន
- រៀបចំផែនការ កាងារ និងថវិកាសម្រាប់ឆ្នាំ២០២៤
- បន្តរៀបចំឯកសារដេញថ្លៃស្តីពីការងារកៀពង្រាបដីស្រែដោយបច្ចេកវិទ្យាប្រព័ន្ធឡាស៊ែ (Laser land leveling) នៅតាមបណ្តាប្រពន្ធ័ធារាសាស្រ្តដែលទើបានសាងសង់រួច។

### ខ. ការងារសម្រាប់ ក្រសួងក្រសួងធនធានទឹក និងឧតុនិយម៖

- បន្តការងារសាងសង់ប្រពន្ធ័ធារាសាស្រ្តដែលនៅសេសសល់ពីត្រីមាសមុន
- បន្តការងារសិក្សាគ្រោងប្លង់(DED)៣អនុគម្រោងដែលនៅសល់ក្នុងខេត្តតាកែវ ដើម្បីបង្គ្រប់សុចនាករគម្រោង ២៧ ប្រពន្ធ័ធារាសាស្រ្ត និងអាចស្រោចបានលើផ្ទៃដី១៥,០០០ហិកតា។
- បន្តការងារសិក្សាគ្រោងប្លង់(DED) និងជ្រើសរើសទីតាំងសាងសង់ស្រះដែលនៅសល់ក្នុងខេត្តទាំង៤ ដើម្បីបង្គ្រប់សុចនាករគម្រោងអោយបាន ៨០០ស្រះ។
- បន្តការងារវាយតម្លៃឯកសារដេញថ្លៃដែលបានបើកសំណើដេញថ្លៃរួចចំនួន៨អនុគម្រោង

### គ. ការងារសម្រាប់ ក្រសួងក្រសួងក្រសួងអភិវឌ្ឍន៍ជនបទ៖

- បន្តការងារវាយតម្លៃឯកសារដេញថ្លៃដែលបានបើកសំណើដេញថ្លៃរួចចំនួន៨អនុគម្រោងដែលមានខ្សែផ្លូវប្រវែង ១០០គីឡូម៉ែត្រ
- បន្តការងារសាងសង់ផ្លូវលំជនបទដែលនៅសេសសល់ពីត្រីមាសមុន សំរាប់កញ្ចប់ទី១ ដែលមានប្រវែង៧១ គីឡូម៉ែត្រ
- បន្តរៀបចំឯកសារដេញថ្លៃសំរាប់អនុគម្រោងក្នុងកញ្ចប់ទី៣ ដែលគម្រោងទាំងនោះបានបញ្ចប់ការងារសិក្សាគ្រោងប្លង់រួច

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ ។ សូម ឯកឧមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**នាយកគម្រោង**
**ខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរ:បរិស្ថាន**

**បណ្ឌិត សំ ឆោមសទ្ធា**

**ចម្លងជូន៖**
- ឯកឧត្តមប្រធានគណៈកម្មាធិការដឹកនាំគម្រោង CFAVC
- ឯកឧត្តមប្រធានអង្គភាពសម្របសម្រួលគម្រោងអភិវឌ្ឍន៍វិស័យ កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ «ដើម្បីជូនជ្រាប»
- នាយកដ្ឋានផែនការ និងស្ថិតិ «ដើម្បីជ្រាប»
- ឯកសារ កាលប្បវត្តិ